**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥-០១៨-២៣០ ស.ជ.ណ

ថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបន្ថែមឥណប្រតិទានប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបថា ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់សន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជានឹងបង្កើតឲ្យមានឥណប្រតិទាន ៣ខែ (៩១ថ្ងៃ) និង ៦ខែ (១៨២ថ្ងៃ) បន្ថែមលើឥណប្រតិទាន ១ឆ្នាំ (៣៦៤ថ្ងៃ) ដែលកំពុងមាន។ ឥណប្រតិទានបន្ថែមទាំងពីរប្រភេទខាងលើនេះ នឹងអនុវត្តចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបជាព័ត៌មាន និងត្រៀមលក្ខណៈចូលរួមការដេញថ្លៃប្រតិបត្តិការ LPCO តាមឥណប្រតិទានដែលចង់បានតាមការគួរ។

សូមទំនាក់ទំនង៖

-អគ្គនាយកដ្ឋានបច្ចេកទេស

-នាយកដ្ឋានប្រតិបត្តិការ

-ទូរស័ព្ទលេខ : (៨៥៥-២៣) ៧២៤ ៩៦៣ ឬ (៨៥៥-២៣) ៧២២ ២២១ EXT. ១០៤៨

-សារអេឡិចត្រូនិក : lpco_info@nbc.org.kh